ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និង ឈ្មោះសំណុំរឿង៖ ១៦០/១១-ហ៊ុយ ចឿន (សាខាមានជ័យ)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល អ៊ឹង សុទ្ធី

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត៖ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ហ៊ុយ ចឿន (ខេមបូឌា) ខប., អិលធីឌី (សាខាមានជ័យ)
អាសយដ្ឋាន ៖ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩២ ៨៨៩ ៩៤៧ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- កញ្ញា សុខ ណារី | ប្រធានរដ្ឋបាល |
| ២- លោក ម៉ុម ធន | ទីប្រឹក្សាក្រុមហ៊ុន |
| ៣- កញ្ញា ឃឹម បូផា | ជំនួយការរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ
- សហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃរោងចក្រស្បែកជើង ហ៊ុយ ចឿន
អាសយដ្ឋាន ៖ ផ្លូវជាតិលេខ១ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១៧ ៧៨៤ ៤៦៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក វឹម បូរ៉ា ប្រធានសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ

២- លោក ចាន់ រស្មី ប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរប្រចាំរោងចក្រ

៣- លោក សួន ពៅពិសី ទីប្រឹក្សាសហជីព

៤- លោក ហ៊ែល ពិសី អនុប្រធានទី២ សហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរប្រចាំក្រុមហ៊ុន ហ៊ុយ ចៀន ទាមទារឱ្យក្រុមហ៊ុនអនុវត្តនូវចំណុចព្រមព្រៀងទាំងអស់ ដែលបានធ្វើនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទាំងពីរលើក គឺនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ និងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ រួមមានចំណុច ៖

- សុំឱ្យក្រុមហ៊ុនបិទផ្សាយអំពីខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តនូវបន្ទប់បំបៅដោះកូន និងទារកដ្ឋាន។
- ការរៀបចំកន្លែងអង្គុយហូបបាយ តុ និងប្រក់ដំបូលបន្ថែមឱ្យបានគ្រប់គ្រាន់ និងសមរម្យ។
- សុំឱ្យមានការតម្លើងប្រាក់ឈ្នួលជូនកម្មករមានជំនាញដូចដែលបានសន្យា។
- ក្រុមហ៊ុនមិនត្រូវបន្តប្រើកម្មករទូទៅឱ្យបោសសំអាតតាមការបែងចែកជាវេនជំនួសអ្នកអនាម័យ។
- ក្រុមហ៊ុនមិនត្រូវបន្តការគុំគួន រើសអើងចំពោះថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ដូចជាការព្យួរការងារថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរ។

ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ៖

- ក្រុមហ៊ុនបានអនុវត្តបិទផ្សាយអំពីខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីបន្ទប់បំបៅដោះកូន និងទារកដ្ឋានរួចហើយ។
- ក្រុមហ៊ុនបានរៀបចំតង់ឱ្យកម្មករនិយោជិតហូបបាយ ហើយបញ្ហាដំបូល គឺក្រុមហ៊ុនបានប្រក់ហើយពុំមានការលិចធ្លុះធ្លាយនោះទេ។
- ចំពោះបញ្ហាប្រាក់ឈ្នួល ដែលត្រូវតំឡើងទៅឱ្យកម្មករនិយោជិតដែលមានជំនាញនោះ គឺក្រុមហ៊ុនបានតំឡើងឱ្យទៅតាមឋានៈ និងជំនាញរបស់ពួកគេរួចរាល់ហើយ។
- ក្រុមហ៊ុនប្រើកម្មករទូទៅឱ្យបោសសំអាត អនុវត្តតាមកិច្ចព្រមព្រៀងនៅអាជ្ញាកណ្តាល។
- ក្រុមហ៊ុនមិនបានរើសអើង និងគុំគួនទៅលើថ្នាក់ដឹកនាំសហជីពឡើយ។

២- ថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនតំឡើងប្រាក់ឈ្នួលគោលចំនួន ៥ ដុល្លារបន្ថែមទៀត ឱ្យដល់កម្មករនិយោជិតទាំងអស់ ដូចដែលបានអនុវត្តនៅរោងចក្រធំ (រោងចក្រ ៦

ជាន់)។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចឱ្យបានទេ ចំពោះការទាមទារតំឡើងប្រាក់ឈ្នួលគោលនេះ។

៣- ថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរទាមទារឱ្យក្រុមហ៊ុនទទួលយករូបលោក (ចាន់ រស្មី) ចូលធ្វើការងារជាធម្មតាវិញ ព្រោះក្រុមហ៊ុនបានបញ្ឈប់រូបលោក ដោយហេតុរើសអើងសហជីព។ ដោយឡែកភាគី ក្រុមហ៊ុនមិនអាចទទួលយកលោក ចាន់ រស្មី ដែលជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរប្រចាំក្រុមហ៊ុន ឱ្យចូលធ្វើការវិញបានទេ ដោយហេតុថា រូបលោកបានក្លែងបន្លំសំបុត្រពេទ្យ ហើយក្រុមហ៊ុនបានព្យួរការងារ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

៤- ថ្នាក់ដឹកនាំសហជីពកម្មករប្រជាធិបតេយ្យខ្មែរ សុំឱ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពជ្រៀតជ្រែក បំភិតបំភ័យកម្មករនិយោជិត ដែលបានប្រព្រឹត្តឡើងដោយលោក ឈុំ វាសនា នាពេលកន្លងមក។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនបានជ្រៀតជ្រែកសហជីព និងបៀតបៀន បំភិតបំភ័យដល់កម្មករនិយោជិតឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៣២៨ ក.ប/អក/វ.ក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល “ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ” ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពកម្មករប្រជាធិបតេយ្យខ្មែរ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន០៤ចំណុចនេះ ត្រូវបានបញ្ជូនមក

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៣២៨ កប/អក/វក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញ ភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ២ និង០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៤ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាត្រង់ ចំណុចវិវាទទី១: ពោល គឺមកដល់ថ្ងៃសវនាការនេះ និយោជកបានអនុវត្តនូវចំណុចទាំងអស់នៃចំណុចវិវាទទី១នេះហើយ និងចំណុចវិវាទទី២ ភាគីកម្មករនិយោជិតបានដកចេញពីការទាមទារវិញ ពីព្រោះក្រុមហ៊ុនបានតម្លើងប្រាក់ឈ្នួលគោលចំនួន ៥ ដុល្លារអាមេរិកដល់កម្មករនិយោជិតដូចដែលបានអនុវត្តនៅរោងចក្រធំ (រោងចក្រ ៦ ជាន់)។ ហេតុនេះ ចំណុចវិវាទចំណុចវិវាទទី៣ និងទី៤ ដែលនៅសល់ ភាគីកម្មករនិយោជិតយល់ព្រមដាក់បញ្ចូលជាវិវាទតែមួយគឺ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន បញ្ឈប់ការព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី ជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ឱ្យចូលធ្វើការជាធម្មតាវិញ ដោយគិតប្រាក់រំលឹក ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើ ចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេចដែល ជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ច ក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទផលប្រយោជន៍។

ការចេញសេចក្តីបង្គាប់លើសំណុំរឿងនេះ ត្រូវបានពន្យារដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប (សាខាកណ្តាល) លេខ ១៨០-២០១១ អពដ/សខ/កណ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១។

២- លិខិតបញ្ជាក់លេខ ៧៧១/២០១១ របស់វេជ្ជបណ្ឌិត ហេង ថេងសំណាង ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១១។

៣- លិខិតរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប.អិលធីឌី (សាខាមានជ័យ) គោរពជូនលោក ចាន់ រស្មី ស្តីពីសុំព្យួរការងារឈ្មោះ ចាន់ រស្មី អត្តលេខ A-2014 មុខងារជាងម៉ាស៊ីន មួយរយៈ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

៤- លិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា) ខប., អិលធីឌី (សាខាមានជ័យ) គោរពជូនលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការស្នើសុំផ្ទេរសិទ្ធិជូនកញ្ញា សុខ ណារី និង លោក ម៉ុម ធន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១។

៥- សារណារបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប. អិលធីឌី (សាខាមានជ័យ) គោរពជូន លេខាធិការ-ដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណាសង្ខេបរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប. អិលធីឌី (សាខាមានជ័យ) ចុះថ្ងៃទី១២ ខែធ្នូ ឆ្នា២០១១ ។

៦- លិខិតរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប.អិលធីឌី (សាខាមានជ័យ) គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសុំព្យួរការងារឈ្មោះ ចាន់ រស្មី អត្តលេខ A-2014 មុខងារជាងម៉ាស៊ីន មួយរយៈ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ០៦៣/១១ ស.ស.ក.ប.ខ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ របស់សហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ គោរពជូន លោកអាជ្ញាកណ្តាលទាំងបីរូប ក្នុងសំណុំរឿងវិវាទការងាររួមលេខ ១៦០/១១ ស្តីពីការជំទាស់ទៅនឹងឯកសារភស្តុតាងទាំងបីសន្លឹកចុងក្រោយរបស់ភាគីក្រុមហ៊ុន ហ៊ុយ ចៀន។

២- លិខិតរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប.អិលធីឌី (សាខាមានជ័យ) គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសុំព្យួរការងារឈ្មោះ ចាន់ រស្មី អត្តលេខ A-2014 មុខងារជាងម៉ាស៊ីន មួយរយៈ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

៣- លិខិតរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (ខេមបូឌា)ខប.អិលធីឌី (សាខាមានជ័យ) គោរពជូនលោក ចាន់ រស្មី ស្តីពីសុំព្យួរការងារឈ្មោះ ចាន់ រស្មី អត្តលេខ A-2014 មុខងារជាងម៉ាស៊ីន មួយរយៈ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

៤- វិញ្ញាបនប័ត្រសហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃរោងចក្រស្បែកជើង ហ៊ុយ ចៀន ចុះបញ្ជិកាលេខ

២២៧១ ក.ប/វក. ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

៥- លិខិតលេខ ២៤៥ ក.ប ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ថា សហជីពកម្មករប្រជាធិបតេយ្យខ្មែរនៃរោងចក្រស្បែកជើង ហ៊ុយ ចៀន ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត ត្រូវបានចុះបញ្ជិកានៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកានេះតទៅ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ៊ុយ ចៀន (សាខាមានជ័យ) លេខ ១៣២៨ ក.ប/អក/វ.ក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ៊ុយ ចៀន (សាខាមានជ័យ) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ហ៊ុយ ចៀន (សាខាមានជ័យ) មានជួលកម្មករនិយោជិតសរុបចំនួន៩៨០ នាក់។
- សហជីពកម្មករប្រជាធិបតេយ្យខ្មែរក្រុមហ៊ុន ហ៊ុយ ចៀន ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពបានចុះបញ្ជិកាទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ដែលមានលោក ចាន់ រស្មី ជាប្រធាន, លោក ឡាង ឡាក់ ជាអនុប្រធាន និងលោក អ៊ិន ចន្ថា ជាលេខាធិការ។

ចំណុចវិវាទទី៣ និងទី៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការព្យួរការងារលោក ចាន់ រស្មី ជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរឱ្យចូលធ្វើការជាធម្មតាវិញ ដោយគិតរំលឹកប្រាក់ឈ្នួលចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ

- លោក ចាន់ រស្មី ចូលធ្វើការនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ មានមុខងារជាជាងម៉ាស៊ីន និងជាប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ប្រចាំរោងចក្រ ហ៊ុយ ចៀន (សាខាមានជ័យ) ។
- លោក ចាន់ រស្មី មានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ ក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ដោយមិនមានផ្តល់ប្រាក់ឈ្នួលឡើយ និងមិនបានបញ្ជាក់ថា បញ្ឈប់នូវការព្យួរពេលណានោះទេ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា មូលហេតុនៃការព្យួរនេះ គឺដោយសារ លោក ចាន់ រស្មី បានក្លែងបន្លំសំបុត្រពេទ្យ។
- លោក ចាន់ រស្មី បានបញ្ជាក់ថា គាត់បានសុំច្បាប់ឈឺ ដោយមានសំបុត្រពេទ្យត្រឹមត្រូវ ពោលគឺ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ គាត់មិនស្រួលខ្លួន ហើយបានទូរស័ព្ទទៅលោកអនុប្រធានសហជីព ឱ្យប្រាប់បន្តទៅប្រធានក្រុមជាងម៉ាស៊ីនឱ្យជួយសុំច្បាប់ (ឈឺ) នៅថ្ងៃបន្ទាប់ចំនួន ១ថ្ងៃ គឺនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ទៅរដ្ឋបាលក្រុមហ៊ុន។ គាប់ជួនពេលនោះ នៅព្រឹកឡើង ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ក្មួយរបស់លោក ចាន់ រស្មី បានជួបនូវឧប្បទ្ទវហេតុលង់ទឹកស្លាប់ ហេតុនេះ គាត់ក៏បានឱ្យលោកអនុប្រធានសហជីព ប្រាប់ទៅប្រធានក្រុមជាងម៉ាស៊ីនឱ្យជួយសុំច្បាប់ចំនួន ២ថ្ងៃបន្ថែមទៀតគឺ ថ្ងៃទី១២ និងទី១៣ ខែតុលា ឆ្នាំ២០១១ ដោយមូលហេតុ ត្រូវជួយរកសពក្មួយលង់ទឹកស្លាប់។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ប្រធានក្រុមជាងម៉ាស៊ីនបានមកសុំច្បាប់ពីរដ្ឋបាល១ថ្ងៃ ជូនលោក ចាន់ រស្មី ដោយមូលហេតុជាប់រវល់ទៅវិញ មិនមែនឈឺទេ។ នៅថ្ងៃ ទី១២ ខែតុលា ឆ្នាំ២០១១ ប្រធានក្រុមជាងម៉ាស៊ីនបានមកសុំច្បាប់ពីរដ្ឋបាល១ថ្ងៃទៀត ដោយមូលហេតុជាប់រវល់ដដែល។ បន្ទាប់មក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ ប្រធានក្រុមជាងម៉ាស៊ីនមិនបានមកសុំច្បាប់ពីរដ្ឋបាល ជូនលោក ចាន់ រស្មី ទៀតទេ។ ពោល គឺ ប្រធានក្រុមជាងម៉ាស៊ីនបានគូសសញ្ញាខ្វែងក្នុងបញ្ជីវត្តមានត្រង់ឈ្មោះលោក ចាន់ រស្មី (មានន័យថា អវត្តមាន)។
- ភាគីក្រុមហ៊ុនបានបញ្ជាក់បន្ថែមថា នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ គាប់ជួន ត្រូវមានសវនាការអាជ្ញាកណ្តាល សំណុំរឿងលេខ ១២៦/១១-ហ៊ុយ ចៀន សហជីពបានស្នើសុំពន្យារពេលសវនាការ ដោយសារលោក ចាន់ រស្មី ប្រធានសហជីពបានជួបនូវឧប្បទ្ទវហេតុ ក្មួយលង់ទឹកស្លាប់ មិនមែនដោយសារឈឺនោះទេ ហើយក្រុមហ៊ុនបានយល់ព្រមពន្យារពេលសវនាការ តាមការស្នើសុំផងដែរ។ ប៉ុន្តែ បែរជានៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ លោក ចាន់ រស្មី ចូលមកធ្វើការវិញ មានភ្ជាប់នូវសំបុត្រពេទ្យបញ្ជាក់ថា គាត់ឈឺខ្លួនឯងទៅវិញ។ ដោយមូលហេតុនេះ និយោជកបានលើកឡើងថា រដ្ឋបាលក្រុមហ៊ុនបានជួបផ្ទាល់ជាមួយនឹងលោកវេជ្ជបណ្ឌិត ដែលបានចេញសំបុត្រពេទ្យ លេខ ៧៧១/២០១១ ចុះថ្ងៃ ទី១៤ ខែតុលា ឆ្នាំ២០១១ ឱ្យលោក ចាន់ រស្មី ឈប់សម្រាកដោយមានជម្ងឺចំនួន៣ថ្ងៃ។ លោកវេជ្ជបណ្ឌិតបានសរសេរបញ្ជាក់ក្នុងលិខិត

មួយជូនដល់ក្រុមហ៊ុន ចុះថ្ងៃទី ទី១៤ ខែតុលា ឆ្នាំ២០១១ ដដែល ដែលបញ្ជាក់ថា លោក ចាន់ រស្មី បានអង្វរករឱ្យគាត់ធ្វើលិខិតបញ្ជាក់នេះ ដើម្បីកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលគាត់នៅថ្ងៃដែលគាត់ឈប់សម្រាកចំនួន ៣ថ្ងៃ នោះប៉ុណ្ណោះ (ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួល លោក ចាន់ រស្មី ក្នុងពេលបីថ្ងៃនោះ)។ លោក ចាន់ រស្មី មិនបានឈឺពិតប្រាកដនោះទេ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ក្រុមហ៊ុនព្យួរកិច្ចសន្យាការងារលោក ចាន់ រស្មី ដោយសារការរើសអើងសហជីព ពីព្រោះ លោក ចាន់ រស្មី ជាប្រធានសហជីព។
- នៅក្នុងសវនាការក្រុមហ៊ុនបានបញ្ជាក់ថា ការព្យួរនេះ គឺដើម្បីរង់ចាំការសម្រេចរបស់អធិការការងារ។
- នៅថ្ងៃសវនាការ ភាគីក្រុមហ៊ុនបានដាក់លិខិតសុំព្យួរកិច្ចសន្យាការងារលោក ចាន់ រស្មី មួយរយៈ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានសួរបញ្ជាក់ទៅក្រុមហ៊ុនពាក់ព័ន្ធនឹងលិខិតសុំព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី។ ភាគីក្រុមហ៊ុនឆ្លើយថា លិខិតសុំព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី គឺមានតែមួយនេះទេ ដែលក្រុមហ៊ុនដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដូចដាក់ជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លិខិតសុំព្យួរកិច្ចសន្យាការងារលោក ចាន់ រស្មី នេះ គឺសរសេរគោរពជូនលោក ចាន់ រស្មី ដោយមិនសរសេរគោរពជូនទៅនាយកដ្ឋានវិវាទការងារទេ។
- នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ ក្រុមហ៊ុនបានផ្តល់លិខិតសុំព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី មួយរយៈ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺសរសេរគោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ដោយមានត្រាបញ្ជាក់ថ្ងៃចូល នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១។ ទាក់ទងនឹងលិខិតនេះ ភាគីសហជីពបានផ្តល់លិខិតជំទាស់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយលើកឡើងថា ក្នុងសវនាការ ភាគីនិយោជកបានលើកឡើងថា គាត់មានលិខិតព្យួរកិច្ចសន្យាការងាររបស់ លោក ចាន់ រស្មី តែមួយប៉ុណ្ណោះ ប៉ុន្តែ ក្រោយសវនាការ បែរជាមានលិខិតសុំព្យួរកិច្ចសន្យាគាត់ទៅនាយកដ្ឋានវិវាទការងារទៅវិញ។
- ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលភស្តុតាងទាក់ទង នឹងលិខិតស្នើសុំបញ្ឈប់លោក ចាន់ រស្មី ទៅអធិការការងារនោះទេ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី៣ និងទី៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការព្យួរការងាររបស់លោក ចាន់ រស្មី មានតួនាទីប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ឱ្យចូលធ្វើការជាធម្មតាវិញ ដោយគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិ ឬវិវាទអំពីផលប្រយោជន៍?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញាណាមួយចែងពីការទាមទារនោះ*"។ (*សូមមើលសេចក្តីម្តោះអាជ្ញា*

*កណ្តាលលេខ ០៥/១១-អ៊ឹម វើ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៧/១១-ហ្គូលកាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៨/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ចាន់ រស្មី ប្រធានសហជីពកម្មករប្រជាធិបតេយ្យខ្មែរ ចូលធ្វើការជាធម្មតាវិញ ពីព្រោះក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ លោក ចាន់ រស្មី ដោយសារក្រុមហ៊ុនរើសអើងសហជីព។ ចំណែកឯក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនព្យួរកិចសន្យាការងារលោក ចាន់ រស្មី ពីព្រោះលោក ចាន់ រស្មី បានក្លែងបន្លំសំបុត្រពេទ្យ ។ ដោយសារករណីនេះទាក់ទងនឹងការព្យួរកិច្ចសន្យាការងាររបស់ប្រធានសហជីពដែលទាក់ទងនឹង មាត្រា២៩៣ មាត្រា២៩៥ និងប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ ។ ហេតុនេះ វិវាទនេះ ជាវិវាទអំពីសិទ្ធិ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកបានចាត់វិធានការព្យួរកិច្ចសន្យាការងាររបស់លោក ចាន់ រស្មីទៅតាមនីតិវិធី ដែលកំណត់សម្រាប់ថ្នាក់ដឹកនាំសហជីព ទៅតាមច្បាប់ដែរ ឬទេ?

ភាគីនិយោជកបានអះអាងថា ខ្លួនបានព្យួរកិច្ចសន្យាការងាររបស់លោក ចាន់ រស្មី ដោយយល់ឃើញថាលោក ចាន់ រស្មី បានបន្លំឯសារពេទ្យ ។ ប៉ុន្តែតាមការអះអាងរបស់លោក ចាន់ រស្មី និងតាមការបញ្ជាក់របស់លោកគ្រូពេទ្យព្យាបាលឈ្មោះ (វេជ្ជ) ហេង ថេងសំណាង ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ថា ឈ្មោះ ចាន់ រស្មី ភេទប្រុស អាយុ ២៦ឆ្នាំ ទីលំនៅភូមិកណ្តាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល មុខរបរជាកម្មករមានជំងឺចូលព្យាបាលថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ ។ ក្នុងលិខិតនេះ បញ្ជាក់ផងដែរថា ឈ្មោះ ចាន់ រស្មី ឈប់សម្រាកព្យាបាលរយៈពេល៣ថ្ងៃ ។ ប៉ុន្តែលោកវេជ្ជបណ្ឌិត ហេង ថេងសំណាង បានបញ្ជាក់លើលិខិតមួយផ្សេងទៀតនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ដដែល ជូនទៅក្រុមហ៊ុនដោយបញ្ជាក់ថា គាត់បានបញ្ជាក់ឱ្យលោក ចាន់ រស្មី ដោយសារលោក ចាន់ រស្មី បានអង្វរគាត់ឱ្យជួយបញ្ជាក់ថា គាត់ឈឺតែតាមការពិតគាត់ជាប់រវល់រកសពក្មួយដែលលង់ទឹកស្លាប់តាំងពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ។

យោងតាមអង្គហេតុ និយោជកមិនបានចាត់វិធានការអ្វី ក្រៅពីការព្យួរកិច្ចសន្យាការងាររបស់លោក ចាន់ រស្មី ដោយឥតកំណត់រយៈពេលនោះទេ ។

មាត្រា២៩៣ នៃច្បាប់ស្តីពីការងារបានចែងថា "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*

*អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់... ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយពីទទួលពាក្យបណ្តឹង ។...*

*បើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារ ក្នុងរយៈពេលដែលបានកំណត់ឱ្យទេ...ពាក្យបណ្តឹង ...ត្រូវចាត់ទុកថាបានបដិសេធចោល*" ។

មាត្រានេះ ក៏ត្រូវបានអនុវត្តចំពោះថ្នាក់ដឹកនាំសហជីពផងដែរ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលចែងថា *"... ការការពារនេះ ត្រូវបានផ្តល់ឱ្យថ្នាក់ដឹកនាំសហជីព ០៣ រូបក្នុងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ"* ។

យោងតាមមាត្រា២៩៣ នៃច្បាប់ស្តីពីការងារ គឺតម្រូវឱ្យនិយោជកធ្វើលិខិតស្នើសុំបញ្ឈប់កម្មករនិយោជិត ដែលកម្មករនិយោជិតអាចជាប្រតិភូបុគ្គលិក ឬក៏ជាថ្នាក់ដឹកនាំសហជីពទៅអធិការការងារ។ រីឯមាត្រា ២៩៥ នៃច្បាប់ស្តីពីការងារ គឺអនុញ្ញាតឱ្យនិយោជកធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនោះសិន ប្រសិនបើនិយោជកយល់ឃើញថា កម្មករនិយោជិតបានប្រព្រឹត្តកំហុសធ្ងន់។ តាមន័យខាងលើនេះ និយោជកអាចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតដែលខ្លួនយល់ថា បានប្រព្រឹត្តកំហុសធ្ងន់ ប៉ុន្តែទន្ទឹមនឹងនោះ និយោជកត្រូវដាក់ ពាក្យស្នើសុំបញ្ឈប់កម្មករនិយោជិតនោះទៅអធិការកិច្ចការងារដែរ ប្រសិនបើនិយោជកមានចេតនាបញ្ឈប់កម្មករនិយោជិតនោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្យួរកិច្ចសន្យាការងារ មិនតំរូវឱ្យនិយោជកស្នើសុំទៅអធិការការងារនោះទេ។ គោលបំណងនៃមាត្រា ២៩៥ គឺអនុញ្ញាតឱ្យនិយោជកធ្វើការព្យួរ ប៉ុន្តែមាត្រានេះ ក៏តំរូវឱ្យនិយោជកទន្ទឹមនឹងពេលនោះធ្វើការស្នើសុំបញ្ឈប់ទៅអធិការការងារភ្លាមៗដែរ ដោយជៀសវាងការអូសបន្លាយពេលវេលាដែលធ្វើឱ្យកម្មករនិយោជិតបាត់បង់នូវ អត្ថប្រយោជន៍ដែលខ្លួនត្រូវទទួលបាន។ មាត្រា២៩៥ ក៏បានបញ្ជាក់ដែរថា ប្រសិនបើអធិការការងារមិនយល់ព្រមចំពោះការបញ្ឈប់នោះទេ ការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតត្រូវទុកជាមោឃៈ។ ហេតុនេះមានន័យថា កម្មករនិយោជិតត្រូវទទួលបាននូវប្រាក់ឈ្នួលនៅក្នុងកំឡុងពេលដែលបានព្យួរនោះ។ ទាក់ទងនឹងរយៈពេល ដែលអធិការការងារត្រូវឆ្លើយតបចំពោះការបញ្ឈប់ គឺមាត្រា២៩៣ ទុករយៈពេលឱ្យអធិការការងារចំនួន១ខែ ប៉ុណ្ណោះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានធ្វើការស្នើសុំព្យួរ ប៉ុន្តែមិនបានស្នើសុំបញ្ឈប់ទៅអធិការការងារ នៅក្នុងកំឡុងពេលព្យួរតាមការចង្អុលបង្ហាញតាមមាត្រា២៩៥ មកដល់ពេលនេះ ហើយក៏មិនមានការឆ្លើយតបណាមួយ ពីអធិការការងារនោះដែរ។ នេះមានន័យថា និយោជកបានធ្វើខុសទៅនឹងនីតិវិធីដែលចង្អុលបង្ហាញដោយច្បាប់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្យួរការងារតាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ រហូតមកដល់ពេលនេះ គឺធ្វើឱ្យកម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួលទាល់តែសោះ គឺមិនត្រឹមត្រូវទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកបញ្ចប់ការព្យួរកិច្ចសន្យាការងាររបស់ លោក ចាន់ រស្មី និងទទួលយកចូលធ្វើការវិញ ដោយគិតរំលឹកប្រាក់ឈ្នួល ចាប់តាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ រហូតមកដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

**ចំណុចវិវាទទី៣ និងទី៤ ៖**

បង្គាប់ឱ្យនិយោជកបញ្ចប់ការព្យួរកិច្ចសន្យាការងាររបស់ លោក ចាន់ រស្មី និងទទួលយកចូលធ្វើការវិញ ដោយគិតរំលឹកប្រាក់ឈ្នួល ចាប់តាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ រហូត មកដល់ថ្ងៃចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ។

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន**

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ១៦០/១១- ហ៊ុយ ចឿន**

## យោបល់ជំទាស់ទៅសេចក្តីសម្រេចនៃសំណុំរឿង ហ៊ុយ ចឿន
## ដោយអាជ្ញាកណ្តាល អ៊ឹង សុទ្ធី ដែលជ្រើសរើសដោយភាគីនិយោជក

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់សេចក្តីសម្រេចរបស់ខ្លួន ក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប ។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្តីបង្គាប់នោះ "* ។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **អ៊ឹង សុទ្ធី** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ **១៦០/១១- ហ៊ុយ ចឿន** ចំណុចវិវាទទី៣ ដែលបង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលសងរំលឹកទៅឱ្យកម្មករ ចាន់ រស្មី ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ ។

ខ្ញុំសូមបញ្ជាក់ អំពីមូលហេតុនៃការជំទាស់ ដូចមានក្នុងសេចក្តីអត្ថាធិប្បាយខាងក្រោមនេះ ៖

ការបង្គាប់បញ្ជាឱ្យនិយោជកត្រូវបើកប្រាក់ឈ្នួលសងរំលឹកទៅឱ្យកម្មករ ចាន់ រស្មី ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ខ្ញុំបានសូមជំទាស់ ត្បិតអីមាត្រា ៧២/១ នៃច្បាប់ស្តីពីការងារបានចែងថា "ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់ចំពោះកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ច ដែលកម្មករនិយោជិតត្រូវធ្វើការឱ្យ និយោជក និងកាតព្វកិច្ច ដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត " ។

ហើយប្រសិនបើយោងតាមមាត្រា ៧១ ក/២ ១២ នៃច្បាប់ស្តីពីការងារបានចែងថា " និយោជកនឹងអាចបញ្ចប់ការព្យួរកិច្ចសន្យាការងារបាន លុះត្រាតែបុព្វហេតុទាំងឡាយនៃការព្យួរកិច្ចសន្យានេះ បានផុតរលត់ ហើយលុះត្រាតែនិយោជកបានឱ្យដំណឹងមុនតាមច្បាប់ទៀតផង " ។

ដូច្នេះ ការលើកឡើងរបស់និយោជក និងខ្លឹមសារនៃមាត្រា ៧១ ក/ខ ១២ នៃច្បាប់ស្តីពីការងារខាងលើបានបញ្ជាក់ថា បុព្វហេតុនៃការព្យួរកិច្ចសន្យានេះ កំពុងស្ថិតក្នុងនីតិវិធីបន្ត ដែលនិយោជកត្រូវចាត់វិធានការបន្តទៀត ដោយមូលហេតុថា បុព្វហេតុនៃការព្យួរនេះ កំពុងស្ថិតក្នុងនីតិវិធីបន្ត ដែលនិយោជកត្រូវចាត់វិធានការបន្តទៀត ដោយមូលហេតុថា កម្មករ ចាន់ រស្មី ជាថ្នាក់ដឹកនាំសហជីព ដែលត្រូវទទួលបានការការពារពិសេស ។ ហើយក្នុងមាត្រា ៧២ ក/ខ ១ បានបញ្ជាក់ថា លុះត្រាតែមានបទប្បញ្ញត្តិណាមួយ ចែងកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យទៅកម្មករនិយោជិតនោះ ។

ប៉ុន្តែមកទល់ពេលនេះ យើងមិនឃើញមានបទប្បញ្ញត្តិណាមួយចែងកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យទៅកម្មករនិយោជិតនោះទេ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១

ហត្ថលេខារបស់អាជ្ញាកណ្តាល

**អ៊ឹង សុទ្ធី**